ក

# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១១-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤៣០ ស្ដីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម និងអស់លោក ចំនួន ០៦ រូប ២៩២៧

១១-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤៣១ ស្ដីពីការតែងតាំង ឯកឧត្តម ហ៊ី ម៉ុនគីម ជាទីប្រឹក្សាអមក្រសួងអភិវឌ្ឍន៍ជនបទ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ២៩២៨

១១-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤៣២ ស្ដីពីការតែងតាំង ឯកឧត្តម មាស ម៉ូនីតា ជាអនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន ២៩២៩

១១-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤៣៣ ស្ដីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ នាយទាហាន ចំនួន ២២ រូប ២៩៣០

១១-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤៣៤ ស្ដីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ នាយទាហានជាន់ខ្ពស់ និងនាយទាហាន ចំនួន ៤៣ រូប ២៩៣១

១១-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤៣៥ ស្ដីពីការតែងតាំង ឯកឧត្តម អ៊ិន ឆាយ ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយក ២៩៣៣

១១-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤៣៦ ស្ដីពីការប្រោសព្រះរាជទាន ចំពោះឧត្តមសេនីយ៍ត្រី ហែម ថេង នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ២៩៣៤

១១-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤៣៧ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឧកញ៉ា.អស់លោក និងព្រះសង្ឃ ចំនួន ០៥ រូប ២៩៣៥

១៨-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤៣៨ ស្ដីពីការតែងតាំង អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ជាតិមុន្នី ជាឯកអគ្គរាជទូតអមព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ២៩៣៦

២០-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤៣៩ ស្ដីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម និងអស់លោក ចំនួន ៤៩ រូប ២៩៣៧

២០-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤៤០ ស្ដីពីការតែងតាំង ឯកឧត្តម ថូ សំអាថ ជាទីប្រឹក្សាឯកឧត្តម ខួន ញ៉ឹល អនុប្រធានទី ១ រដ្ឋសភា នីតិកាលទី ៤ មានឋានៈស្មើ អគ្គនាយក ២៩៣៩

២២-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤៤២ ស្ដីពីការតែងតាំង ឯកឧត្តម ឯក សេរីវឌ្ឍ ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី ២៩៤០

២២-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤៤៣ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម និងអស់លោក ចំនួន ២៦ រូប ២៩៤១

២២-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤៤៤ ស្តីពីការប្រោសព្រះរាជទាន ប្រគេនចំពោះព្រះសង្ឃ ចំនួន ០២ អង្គ នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ២៩៤៣

២២-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤៤៥ ស្តីពីការតែងតាំង ឯកឧត្តម សុខ ស៊ុនលីន ជាឧកញ៉ា ២៩៤៤

២២-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤៤៦ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ ឯកឧត្តម និងអស់លោក ចំនួន ០៨ រូប ២៩៤៥

២២-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤៤៧ ស្តីពីការតែងតាំង សមាសភាពថ្នាក់ដឹកនាំ នៃគណៈកម្មាធិការជាតិអេស្កាប់ និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិអេស្កាប់ ចំនួន ០៩ រូប ២៩៤៦

២២-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤៤៨ ស្តីពីការតែងតាំង ឥស្សរជនចំនួន ០២ រូប ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ២៩៤៨

២២-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤៤៩ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ជូនចំពោះ អស់លោក ចំនួន ០២ រូប ២៩៤៩

## II-រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

២៧-៤-២០០៩ -អនុក្រឹត្យលេខ ៦៥ អនក្រ.បក ស្តីពីការនិរាករណ៍អនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០០៩ ស្តីពីការបិទស្ថានប្រតិភូអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជាប្រចាំអង្គការយូណេស្កូ នៅទីក្រុងប៉ារីស ២៩៥០

២៧-៤-២០០៩ -អនុក្រឹត្យលេខ ៦៦ អនក្រ.បក ស្តីពីការនិរាករណ៍អនុក្រឹត្យលេខ ៥៦១ អនក្រ.តត ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៩ ស្តីពីការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូត ២៩៥១

២៧-៤-២០០៩ -អនុក្រឹត្យលេខ ៦៧ អនក្រ.បក ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការទីភ្នាក់ងារជាតិមុខរបរ និងមុខងារ ២៩៥២

២៧-៤-២០០៩ -អនុក្រឹត្យលេខ ៦៨ អនក្រ.បក ស្តីពីការបង្កើត គណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធិភាពការងារ និងគណនេយ្យភាព ២៩៦០

២៧-៤-២០០៩ -អនុក្រឹត្យលេខ ៥៨៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៩៦៥

២៧-៤-២០០៩ -អនុក្រឹត្យលេខ ៥៨៧ អនក្រ.តត ស្តីពីការតែងតាំងមុខតំណែង នាយនគរបាលជាតិ ២៩៧០

២៧-៤-២០០៩ -អនុក្រឹត្យលេខ ៥៨៨ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ២៩៧២

២៧-៤-២០០៩ -អនុក្រឹត្យលេខ ៥៨៩ អនក្រ.តត ស្ដីពីការតម្លើងឋានន្តរស័ក្តិ នាយនគរបាលជាតិ ២៩៧៣
២៧-៤-២០០៩ -អនុក្រឹត្យលេខ ៥៩០ អនក្រ.តត ស្ដីពីការតែងតាំងមុខតំណែង នាយនគរបាលជាតិ ២៩៧៤
២៧-៤-២០០៩ -អនុក្រឹត្យលេខ ៥៩១ អនក្រ.តត ស្ដីពីការអនុវត្តវិន័យ នាយនគរបាលជាតិ ២៩៧៥
២៧-៤-២០០៩ -អនុក្រឹត្យលេខ ៥៩២ អនក្រ.តត ស្ដីពីការតែងតាំងសមាសភាពគណៈកម្មការសុរិយោដីថ្នាក់ជាតិ ២៩៧៦
២៧-៤-២០០៩ -អនុក្រឹត្យលេខ ៥៩៣ អនក្រ.តត ស្ដីពីការផ្លាស់ប្ដូរសមាជិកនៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ២៩៧៨
២៧-៤-២០០៩ -អនុក្រឹត្យលេខ ៥៩៤ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៩៨០
២៨-៤-២០០៩ -អនុក្រឹត្យលេខ ៥៩៥ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៩៨១
២៨-៤-២០០៩ -អនុក្រឹត្យលេខ ៥៩៦ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ២៩៨៣
២៨-៤-២០០៩ -អនុក្រឹត្យលេខ ៥៩៧ អនក្រ.តត ស្ដីពីការជូនមេដាយសុវត្ថារា ២៩៨៤
២៨-៤-២០០៩ -អនុក្រឹត្យលេខ ៥៩៨ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២៩៨៥
២៨-៤-២០០៩ -អនុក្រឹត្យលេខ ៥៩៩ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ២៩៨៦
២៨-៤-២០០៩ -អនុក្រឹត្យលេខ ៦០០ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ២៩៨៧
២៨-៤-២០០៩ -អនុក្រឹត្យលេខ ៦០១ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ២៩៨៩
២៨-៤-២០០៩ -អនុក្រឹត្យលេខ ៦០២ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២៩៩១

## ២.សេចក្ដីសំរេច

៣០-៤-២០០៩ -សេចក្ដីសំរេចលេខ ២៨ សសរ ស្ដីពីការបង្កើតគណៈកម្មការសិក្សា វាយតម្លៃតំបន់អភិវឌ្ឍន៍ អាងទឹកស្អាត និងរមណីយដ្ឋានក្បាលឆាយ ខេត្តព្រះសីហនុ ២៩៩២

## III.ការងារបណ្ដាក្រសួង

### ១. ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២៤-៤-២០០៩ -ប្រកាសលេខ ៣៨៩ សហវ.ប្រក ស្ដីពីការអនុវត្តន៍កម្មវិធីលុបបំបាត់ពន្ធនាំចូល និងរបាំងមិនមែនពន្ធលើពាណិជ្ជកម្មក្នុងអាស៊ាន សម្រាប់ចំណែកទី ២ នៃបញ្ជីផលិតផលបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ (ICT) ២៩៩៤

### ២. ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

២៣-៤-២០០៩ -ប្រកាសលេខ ២៤៨ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ដឹ ហ្វៀរ មេនូហ្វេកឆ័រីង ខមភេនី បង្កើតរោងចក្រ "ផលិតចំណីសត្វ (សត្វឆ្កែ) និងផលិតផលផ្សេងៗទៀតសម្រាប់សត្វចិញ្ចឹម" ២៩៩៦
២៨-៤-២០០៩ -ប្រកាសលេខ ២៧៧ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្គោលដេន ហ្គេន ស៊ូ ខមភេនី អិល ធី ឌី បង្កើតរោងចក្រ "ផលិតស្បែកជើង" ៣០០១

# ឃ

## ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


១០-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥០៥៤ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដាយនែមីក អ៊ី-គ្រុប** ៣០០៦

១១-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥០៥៥ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យូរ៉េស៊ាន អេគាណុល ឌីវេឡុបមេន (អ៊ី. អ៊ី. ឌី.)** ៣០០៨

១១-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥០៥៧ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សឹង ហ្វូ តាង ហាន់** ៣០១០

១១-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥០៥៩ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គី អេន គី អ៊ិនធើណេសិនណល** ៣០១២

១១-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥០៦០ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដាតា មេនេចមេន សេនធ័រ (ឌីអិមស៊ី)** ៣០១៤

១១-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥០៦១ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី ជី អេច & អ** ៣០១៦

១១-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥០៧៥ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ាត រិគី អ៊ិនធើណេសិនណល លីមីធីត** ៣០១៨

១១-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥០៧៦ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ី អិន អ៊ិច អិល ខូ អិលធីឌី** ៣០២០

១១-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥០៧៧ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្ទីដធេល** ៣០២២

១១-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥០៧៨ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វាស ស៊ីទីស & ត្រេឌីង** ៣០២៤

១១-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥០៨០ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្គោលដេន ជ្រេហ្គន ឃែភីថល** ៣០២៦

១១-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥០៨៦ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិម ជេ ខេ ហ្វូលឌីង** ៣០២៨

១២-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥០៨៨ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សុដាណា អ៊ីមផត អិចផត** ៣០៣០

១២-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥០៨៩ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដាម៉័រ អាគ ណេតវើក** ៣០៣២

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៥/៤៣០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ជូនចំពោះ:
ឯកឧត្តម ជាំ វុទ្ធី

ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ជូនចំពោះ:
ឯកឧត្តម ហួន ចំន្ទភក្តដា

គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ជូនចំពោះ:
១-ឯកឧត្តម ចាន់ នន់វិទ្យា
២-ឯកឧត្តម ជាំ ដារារិទ្ធ
៣-ឯកឧត្តម តាន់ ឫទ្ធី
៤-លោក ខាន់ ចំន្ទវឌ្ឍនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៩០៤.៤៣៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៥

លេខ: ៣៩០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៥
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤៣១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានតមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **ហ៊ី ម៉ិនគីម** ជាទីប្រឹក្សាអមក្រសួងអភិវឌ្ឍន៍ជនបទ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។.

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល.០៩០៤.៤៣៤

លេខ : ៣៨៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ស៊ុន ចិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤៧២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដាឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំង ឯកឧត្តម **មាស ម៉ូនីកា** ជាអនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៩០៤.៤៣៥

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៩*

លេខ : ៣៨៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩
[illegible]ធិការ[illegible]រាជរដ្ឋាភិបាល
[illegible] ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤៣៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ:-

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១ | វរសេនីយ៍ឯក | ផាង គឹមតិច | ០១០៤៣១ | ៥ | វរសេនីយ៍ឯក | សេក យោន | ០០២០៦៤ |
| ២ | វរសេនីយ៍ឯក | ថ្វី គង់ | ០០២០៦៧ | ៦ | វរសេនីយ៍ទោ | ស៊ុន ថាវី | ០១៦៤៥៣ |
| ៣ | វរសេនីយ៍ឯក | អ៊ុច ចន្ធី | ០០២៧៧៣ | ៧ | វរសេនីយ៍ត្រី | ម៉ូត អន្ថារ៉ា | ០២៨៨២៧ |
| ៤ | វរសេនីយ៍ឯក | គង់ សារ៉េន | ០០០៧២៦ | ៨ | វរសេនីយ៍ត្រី | អ៊ុក ហៀនពិសី | ០៣០១១៧ |

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :-

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១ | វរសេនីយ៍ឯក | គង់ សារ៉ាន់ | ០០៣២៤១ | ៨ | វរសេនីយ៍ទោ | ឆោម ម៉ិនថន | ០០៩៧៨៨ |
| ២ | វរសេនីយ៍ឯក | គង់ សំណាង | ០០២៨៣៧ | ៩ | វរសេនីយ៍ទោ | តាន់ សិរីសិទ្ធ | ១៤៥៤៤៧ |
| ៣ | វរសេនីយ៍ឯក | ស្វាយ សុធី | ០១១៣៣៩ | ១០ | វរសេនីយ៍ទោ | ឈរ ណារ៉េត | ០០៨៧៦៨ |
| ៤ | វរសេនីយ៍ឯក | លាន បូរិន | ០០២៦៧៧ | ១១ | វរសេនីយ៍ទោ | គុយ សុធី | ០០៣១០៦ |
| ៥ | វរសេនីយ៍ទោ | ជា សំអាត | ០០២៦៧៥ | ១២ | វរសេនីយ៍ទោ | ភោគ សារ៉ាត់ | ០០០៧៩១ |
| ៦ | វរសេនីយ៍ទោ | ណែម សម្បត្តិ | ០២៨៨០៧ | ១៣ | វរសេនីយ៍ទោ | ហង្ស មេត្តា | ០១៥៤១៦ |
| ៧ | វរសេនីយ៍ទោ | យៀង ណារុំ | ០១៣២២២ | ១៤ | វរសេនីយ៍ទោ | គីម ម៉ូលី | ០៣៣២៣១ |

ព្រះហស្តលេខា និងព្រះរាជលញ្ជករ

នរោត្តម សីហមុនី

៣រល.០៩០៤.៤៣៦

លេខ : ៣៩៨ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៩

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤៣៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

-ឧត្តមសេនីយ៍ទោ អួន លន ០០០២៧៧

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

-ឧត្តមសេនីយ៍ត្រី អ៊ុង វណ្ណារិទ្ធ ០០០៩៤៧

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១ | ឧត្តមសេនីយ៍ត្រី | ចាន់ សាម៉ន | ០០០៩៣៥ | ៣ | វរសេនីយ៍ឯក | ជ័ វណ្ណារិទ្ធ | ០០៨៩៤៥ |
| ២ | វរសេនីយ៍ឯក | អ៊ុច ទាន់ឈួន | ០០៣៤៥៦ | | | | |

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១ | វរសេនីយ៍ឯក | យឹម ម៉ុនធឿន | ០០០៩៤៨ | ៤ | វរសេនីយ៍ឯក | ពុធ ប្រិល | ០១៥៥៧២ |
| ២ | វរសេនីយ៍ឯក | មាស សុខុម | ០០២៣០០ | ៥ | វរសេនីយ៍ឯក | និត្យ គីមសេង | ០១៥៥៧៣ |
| ៣ | វរសេនីយ៍ឯក | ឌុក ម៉ុនថន | ០១០៥០៤ | ៦ | វរសេនីយ៍ឯក | ទេព សុន | ០១៥៥៦៦ |

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១ | វរសេនីយ៍ត្រី | ទេព អាំ | ០១៥៥៧៩ | ១១ | វរសេនីយ៍ត្រី | ឆាំ វិបុល | ០២៩១៣២ |
| ២ | វរសេនីយ៍ត្រី | ម៉ែន សុន្ទី | ០១៥៥៧១ | ១២ | វរសេនីយ៍ត្រី | ស៊ឹម សារឿម | ០២៩១៨៦ |
| ៣ | វរសេនីយ៍ត្រី | ថ្មី សាវុធ | ០១៥៥៦៤ | ១៣ | វរសេនីយ៍ត្រី | ដួង លន់ | ០២៩១៥៨ |
| ៤ | វរសេនីយ៍ត្រី | សេង ម៉ុន | ០២៩១៦៤ | ១៤ | វរសេនីយ៍ត្រី | ហុក ចន្ថា | ០៥៧៦៨៧ |
| ៥ | វរសេនីយ៍ត្រី | កោះ ណាត | ០១៨១៥៣ | ១៥ | វរសេនីយ៍ត្រី | កឹង សើរ | ០១៥៥៦៧ |
| ៦ | វរសេនីយ៍ត្រី | សាយ ទាំន់ថា | ០២៩១៤០ | ១៦ | វរសេនីយ៍ទោ | ជួន ម៉ារ៉ាឌី | ០៣២២៧៣ |
| ៧ | វរសេនីយ៍ត្រី | សែ ធី | ០១០៥០៣ | ១៧ | វរសេនីយ៍ត្រី | ស្វាយ សារឿន | ០១០៥០៩ |
| ៨ | វរសេនីយ៍ត្រី | សំ វាសនា | ០២៩១៥០ | ១៨ | វរសេនីយ៍ត្រី | ខួន ស៊ុម | ០១៥៥៨៦ |
| ៩ | វរសេនីយ៍ត្រី | ចាប ឈួន | ០១៥៥៧៧ | ១៩ | វរសេនីយ៍ត្រី | ចាន់ មុនី | ០១៥៥៩០ |
| ១០ | វរសេនីយ៍ត្រី | គុល ហេង | ០១០៥០៦ | ២០ | វរសេនីយ៍ត្រី | វ៉ត្ត ម៉ុនឈឿន | ០១៥៦០២ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២១ | វរសេនីយ៍ត្រី | ឌី ទ៊ាន់ថុន | ១៩៧៦២៨ | ២៧ | អនុសេនីយ៍ឯក | ឃួន សុចន្ទី | ០២៩១៩១ |
| ២២ | វរសេនីយ៍ត្រី | សោម ណារ៉ូ | ០១៩៥៨៧ | ២៨ | អនុសេនីយ៍ឯក | ឆា ម៉េង | ០២៩១៤៤ |
| ២៣ | វរសេនីយ៍ត្រី | ឈុំប សុន | ០១៩៥៨៨ | ២៩ | អនុសេនីយ៍ឯក | ប្រាក់ សុធារុង | ១៩៧៥៩៨ |
| ២៤ | វរសេនីយ៍ត្រី | ឈុំប ហឿន | ០១៩៥៩១ | ៣០ | អនុសេនីយ៍ឯក | ម៉ី រ៉ា | ១៩៧៦០០ |
| ២៥ | វរសេនីយ៍ត្រី | ទូច សារី | ០២៩១៥១ | ៣១ | អនុសេនីយ៍ឯក | ម៉ែន សោភ័ណ | ១៣៥១០១ |
| ២៦ | អនុសេនីយ៍ឯក | លី សារិទ្ធ | ០២៩១៤៣ | ៣២ | អនុសេនីយ៍ទោ | នង ចិសោលសក្តិ | ០២៩១៤៩ |

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកត.០៩០៤.៤៣៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៩

លេខ : ៤០៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤៣៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម អ៊ិន ឆាយ ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៩ល.០៩០៤.៤៣៥

លេខ : ៣៨៦ ច.ល

...ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី... ខែមេសា ឆ្នាំ២០០៩

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៩*

...អគ្គលេខាធិការរាជរដ្ឋាភិបាល

... ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤៣៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឧត្តមសេនីយ៍ត្រី ហែម ថេង អត្តលេខ ០៨៣៨

នូវ

គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៤ល.០៩០៤.៤៣៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៩

លេខ : ៣៩៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចាន់ថុល

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៥/៤៣៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :-

ឧកញ៉ា អ៊ឹង ស៊ា

ខ-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

១-លោក ជា ស៊ិនហ៊ែល

២-លោក ប៊ី ពិទូរ្យ

៣-លោក ឈៅ និមល

គ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ :-

ព្រះគ្រូបញ្ញារង្សី ពេជ្រ សុភាព

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧៧.០៥០៤.៤៤០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០៥

លេខ : ៣៩៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០០៥

...ខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤៣៧

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**តែងតាំង**

**អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ជាតិមង្គល**

**ជា**

**ឯកអគ្គរាជទូតអមព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ**
**មានឋានៈស្មើ អនុរដ្ឋលេខាធិការ**

នរោត្តម សីហមុនី

ពរក.០៩០៤.៤៤១
**បានប្រថាប់ព្រះរាជលញ្ឆករហើយ**

**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០៩

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
លេខ [illegible] រ.ចច
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩
[illegible] ចៅហ្វាវាំង [illegible] វង្សជ័យ អគ្គធិបតីស្រីង្គារ
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង
ROYAUME DU CAMBODGE — LE MINISTRE DU PALAIS
កុង សំអុល

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤៣៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

### ប្រោសព្រះរាជទាន

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១- ឯកឧត្តម អ៊ុត ប្រាំង

ខ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១- ឯកឧត្តម នួន លាន ២- ឯកឧត្តម លី ហាក់

៣- ឯកឧត្តម ឈួន គីមស្រ៊ួន

គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :

១- ឯកឧត្តម លីម អេង ២-លោក ហ៊ួង ឆន់

ឃ- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ចំពោះ :

១- លោក ត្រី ស៊ាងឡុង

ង- គ្រឿងឥស្សរិយយស មុនីសារាភ័ណ ថ្នាក់ មហាសេនា ចំពោះ :

១- លោក ប៊ុន ណារិទ្ធ ២-លោក ឃិន រដ្ឋា

៣- លោក ប៊ី ពិទូរ្យ ៤- លោក ហុង បូណា

៥- លោក ជា ស៊ុនហៀល ៦-លោក ម៉ៅ ស៊ួយពិសិដ្ឋ

៧- លោក ង៉ែ និមល

ច-គ្រឿងឥស្សរិយយស មុនីសារាភ័ណ ថ្នាក់ ធិបឌិន្ទ ចំពោះ :

១- លោក ទិចធ័រ ហ្សូនា ២- លោក មុជ ឈុនហ៊ិន

៣- លោក សៀង សុថាម ៤- លោក ហេង សុភ័ណ្ឌ

៥-លោក យា ប៊ុនណា ៦- លោក ប៊ុន សុទ្ធី

៧-លោក ចាន់ បូរិន្ទ ៨- លោក ចិន សេងហ៊ាង

៩- លោក ថេង ម៉ារិទ្ធ ១០- លោក នួត ម៉េងស្រ៊ុន

១១- លោកបណ្ឌិត ប្រាំង ជលសា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ឆ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | នូ លឹម | ២- លោក | អាច សៅ |
| ៣- លោក | ឯម ជួន | ៤- លោក | អាច ហួច |

ជ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ ថ្នាក់ សេនា ចំពោះ :

| | | | |
|---|---|---|---|
| ១- លោក | អ៊ូ ចាន់រិទ្ធ | ២- លោក | ប៉ែន សុខណ្ណា |
| ៣- លោក | អ៊ី សាហាត់ | ៤- លោក | ម៉ឿច ផា |
| ៥-លោក | ឆេត រាមមុនី | ៦- លោក | ឆន់ សុធី |

ឈ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :

| | | | |
|---|---|---|---|
| ១- លោក | នង ណាន | ២- លោក | ឡៀប លន់ |
| ៣- លោក | គង់ សៃ | ៤- លោក | គែច ន៉ារី |
| ៥- លោក | ហ៊ឹម សារុន | ៦- លោក | ចាន់ ប៊ុត |
| ៧- លោក | សួខ លាច | ៨- លោក | ឃួន សុខែម |

ញ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ ថ្នាក់ អស្សឫទ្ធិ ចំពោះ :

| | | | |
|---|---|---|---|
| ១- លោក | គីម ប៊ុនអាន | ២- លោក | ចែម ពិចិត្រ |
| ៣- លោក | ហ៊ីត ផេង | ៤- លោក | ហេង អៀង |
| ៥-លោក | ហេង គុណលាង | ៦- លោក | ខ្លូត សុខា |

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣៧.០៩០៤.៤៤២

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៩*

លេខ : ៤០៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃួន ជិនកេន

# ព្រះរាជក្រឹត្យ

## យើង

នស/រកត/០៤០៩/៤៤០

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៤ នៃរដ្ឋសភា នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និងថ្នាក់ដឹកនាំរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ច្បាប់ស្តីពីថវិកាប្រចាំឆ្នាំ ២០០៩ របស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ ឯកឧត្តម ខួន ញឹល ប្រធានរដ្ឋសភាស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** .- ត្រូវបានតែងតាំង ឯកឧត្តម ឌូ សំអាង ជាទីប្រឹក្សា ឯកឧត្តម ខួន ញឹល អនុប្រធានទី១ រដ្ឋសភា នីតិកាលទី៤ មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា២** .- សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** .- ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល.០៩០៤.៤៤៣

លេខ : ៤៥៤. ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០០៩

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុំ ម៉ានិត**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៩*

**ស៊ិន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤៤២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្មហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តម **ឯក សេរីវឌ្ឍ** ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

៣រល. ០៩០៤.៤៤៥

**បានប្រថាប់ព្រះរាជលញ្ចករហើយ**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៩*

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

លេខ ... រ.ចច

រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៩

សម្តេចចៅហ្វាវាំង ... អធិបតីស្រីង្គារ

ឧបនាយករដ្ឋមន្ត្រី ... រដ្ឋមន្ត្រីព្រះបរមរាជវាំង

**គង់ សំអុល**

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤៤៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

១. គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជាថ្នាក់មហាសេនា ជូនចំពោះ :

១- ឯកឧត្តម ប៉ាន សូរស័ក្តិ

២- ឯកឧត្តម ឌុច សុន

៣- ឯកឧត្តម វ៉ាន់ ណយ

២. គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជាថ្នាក់សេនា ជូនចំពោះ :

១- លោក លឹម ប៊ុនថន

២- លោក អ៊ឹង ប៊ុនសុវណ្ណ

៣- លោក អ៊ឹង វណ្ណារិន

៤- លោក ចាន់ សុធា

៥- លោក ម៉ឹង វុធី

៦- លោក ហង្ស សុផាណារ៉ា

៧- លោក ជីវ ផល្លី

៣. គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជាថ្នាក់អស្សឫទ្ធិ ជូនចំពោះ :

១- លោក អ៊ួង ចន្ទី

២- លោក គឹម វឌ្ឍនសោភ័ណ

៣- លោក ប៊ុន ណារុំ

៤- លោក លឹម សុខគូ

៥- លោក ចេង មុនីរ៉ា

៦- លោក យឹម សំអុល

៧- លោក ថេង កន្នុំ

៨- លោក លឹម ឆាយ

៩- លោក ស្រ៊ា រតនៈ

១០- លោក បួន ហេង

១១- លោក យស់ វីរៈ

១២- លោក ម៉ន ប៊ុនថារ៉ា

១៣- លោក ដែក សុវិចិត្រ

១៤- លោក ណុប សម្បត្តិ

១៥- លោក យ៉យ ឈួន

១៦- លោក សាត គីមសាន

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

*៣៧.០៩០៤.៤៤៦*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៩*

លេខ : ៤១០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី [illegible]៤ ខែ មេសា ឆ្នាំ២០០៩

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤៤៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

ប្រគេនចំពោះ

១-ព្រះគ្រូសមត្ថត្ថេរ ថោង ស៊្រុន

២-ព្រះគ្រូសិរីគុត្តត្ថេរ ថោង ស្រេង

ទូវ

**គ្រឿងឥស្សរិយយស មុនីសារាភិរណ្ឌ ថ្នាក់ មហាសេនា**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៩០៤.៤៤៧

លេខ : ៤៦១ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៩

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ [illegible] ឆ្នាំ២០០៩
ប្រធានខុទ្ទកាល័យអគ្គរាជរដ្ឋាភិ
ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤៤៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

តែងតាំង

ឯកឧត្តម **សុខ ស៊ុនលីន**

ជា

ឧកញ៉ា

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

៣៧៧.០៩០៤.៤៤៧ **នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៩*

លេខ : ៤១២ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០០៩
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤៤៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

នូវ

**គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :-**

១-ឯកឧត្តម ខួន នៅ
២-ឯកឧត្តម អ៊ុំ ខេង
៣-ឯកឧត្តម ឯក សុនចាន់
៤-ឯកឧត្តម ម៉ាន់ ឈឿន
៥-ឯកឧត្តម ជូ ទិជិត្ត
៦-លោក សែម ប៊ុនហេង
៧-លោក ហុង ស៊ីលីន
៨-លោក នេត មុន្នី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩៧.០៩០៤.៤៤៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២ ២ ខែ មេសា ឆ្នាំ ២០០៩

លេខ : ៤០៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤៤៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១០៩/០២៦ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអេស្កាប់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំងសមាសភាពថ្នាក់ដឹកនាំនៃគណៈកម្មាធិការជាតិអេស្កាប់ ដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១. ឯកឧត្តម **លី ធុជ** | ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស | **ជាប្រធាន** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ២. ឯកឧត្តម **អ៊ូ ឱបាត** | រដ្ឋលេខាធិការក្រសួងផែនការ | **ជាអនុប្រធាន** | បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣. ឯកឧត្តម **សេង លឹមនៅ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | **ជាអនុប្រធាន** | បន្ថែមលើមុខងារបច្ចុប្បន្ន។ |

AUME DU CAMBODGE
ព្រះបរមរាជវាំង
REGISTRE DU PALAIS ROYAL

**មាត្រា ២** : ត្រូវបានតែងតាំងសមាសភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិអេស្កាប់ ដូចខាងក្រោម ÷

១. ឯកឧត្តម **គីម វឌ្ឍនា** ជាអគ្គលេខាធិការ មានឋានៈស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២. ឯកឧត្តម **ចៅ ឡាយ** ជាអគ្គលេខាធិការរង មានឋានៈស្មើអនុរដ្ឋលេខាធិការ

៣. ឯកឧត្តម **យិន ច័ន្ទវាសនា** ជាអគ្គលេខាធិការរង មានឋានៈស្មើអនុរដ្ឋលេខាធិការ

៤. ឯកឧត្តម **តាំ វិបុល** ជាអគ្គលេខាធិការរង មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

៥. ឯកឧត្តម **ស្រ៊ុន លឹមសុង** ជាអគ្គលេខាធិការរង មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

៦. ឯកឧត្តម **មាស បូរ៉ា** ជាអគ្គលេខាធិការរង មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា ៣** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*នរល.០៩០៤.៤៥០*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៩*

លេខ : ៤០៧. ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ មេសា ឆ្នាំ២០០៩

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤៤៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឥស្សរជនចំនួន ០២ រូប ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដូចមានរាយនាមខាងក្រោម ÷

- ឯកឧត្តម **លី គាំ**
- លោកជំទាវ **ឃឹម លីដា**

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

លេខ : ៤១៣ ច.ល

ជម្រាបជូន ចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

**ឃុន ជិនកេន**

៣រល.០៩០៤.៤៥១

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៩*

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៥/៤៤៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** ជូន

១- លោក **ចាន់ សុខជូនា** ប្រធាននាយកដ្ឋានច្បាប់ និង វិវាទកម្ម
នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

២- លោក **អ៊ុំ អិល** ប្រធាននាយកដ្ឋានស្រាវជ្រាវ តម្កល់ឯកសារ និង បណ្ណាល័យ
នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៩០៤.៤៥២

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៥*

លេខ : ៤០៦. ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០០៥
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការនិរាករណ៍អនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៩ ស្តីពីការបិទស្ថានប្រតិភូអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជាប្រចាំអង្គការយូណេស្កូ នៅទីក្រុងប៉ារីស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- តាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** អនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៩ ស្តីពីការបិទស្ថានប្រតិភូអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជាប្រចាំអង្គការយូណេស្កូ នៅទីក្រុងប៉ារីស ត្រូវទុកជានិរាករណ៍។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមេសា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ.*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការនិរាករណ៍អនុក្រឹត្យលេខ ៥៦១ អនក្រ.តត ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៩ ស្តីពីការបញ្ចប់អណត្តិបេសកកម្មមន្ត្រីការទូត

◊◊◊+◊◊◊

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- តាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** អនុក្រឹត្យលេខ ៥៦១ អនក្រ.តត ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៩ ស្តីពីការបញ្ចប់អណត្តិបេសកកម្មមន្ត្រីការទូត ត្រូវទុកជានិរាករណ៍។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ១៩មេសា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួលៈ*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៦៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើត និងដាក់ឱ្យដំណើរការទីភ្នាក់ងារជាតិមុខរបរ និងការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញាឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៨/៣៤៦ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីគោលការណ៍រួមនៃការបង្កើត និងការដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- បានឃើញអនុក្រឹត្យលេខ ៧៩០ អនក្រ.តត ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលមាត្រា ២ នៃអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

**ស ម្រេ ច**

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើត និងដាក់ឱ្យដំណើរការទីភ្នាក់ងារជាតិមុខរបរ និងការងារ សរសេរកាត់ជា "**ឆ.ជ.ម.ក.**" ជាទីភ្នាក់ងារប្រតិបត្តិការពិសេស ដែលស្ថិតនៅក្រោមគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដោយមានអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈជាសេនាធិការ ដើម្បីសម្របសម្រួល និងផ្តល់ព័ត៌មានពាក់ព័ន្ធទៅនឹងទីផ្សារការងារនៅព្រះរាជាណាចក្រកម្ពុជាឱ្យដំណើរការបានល្អប្រសើរ ។

**មាត្រា ២.-**

**ឆ.ជ.ម.ក.** ត្រូវបានបង្កើតឡើងក្នុងគោលបំណង លើកកំពស់ការផ្តល់សេវាព័ត៌មានទីផ្សារការងារប្រកបដោយគុណភាព និងប្រសិទ្ធភាព ដើម្បីផ្តល់ឱកាសឱ្យអ្នកស្វែងរកការងារ និយោជិត និយោជក និងអ្នកផ្តល់ការបណ្តុះបណ្តាលជំនាញ មានលទ្ធភាពទទួលបានព័ត៌មានពីគ្នាទៅវិញទៅមក ។

## ជំពូកទី ២
## បេសកកម្ម តួនាទី និងភារកិច្ច

**មាត្រា ៣.-**

**ឆ.ជ.ម.ក.** មានតួនាទី និងភារកិច្ចចម្បងៗ ដូចខាងក្រោម :

- សម្របសម្រួល និងរៀបចំឱ្យមានសេវាព័ត៌មានការងារ មុខរបរ និងការអប់រំបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ
- ផ្តល់សេវាព័ត៌មានឱ្យអ្នករកការងារ និយោជិត និយោជក អ្នកផ្តល់ការបណ្តុះបណ្តាលជំនាញ និងសាធារណជន មានលទ្ធភាពទទួលបានព័ត៌មានពីគ្នាទៅវិញទៅមក ប្រកបដោយប្រសិទ្ធភាពក្នុងរូបភាពព័ត៌មានជាលក្ខណៈចំហ និងបង្កឱកាសឱ្យភាគីពាក់ព័ន្ធបានជួបគ្នាតាមរយៈការផ្សព្វផ្សាយ និងកម្មវិធីនានារបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ
- សិក្សាស្រាវជ្រាវ និងអភិវឌ្ឍប្រព័ន្ធព័ត៌មានទីផ្សារការងារ ឱ្យសមស្របទៅនឹងការវិវឌ្ឍន៍នៃសេដ្ឋកិច្ចសង្គម នាពេលបច្ចុប្បន្ន និងទៅអនាគត

- ជំរុញផ្សព្វផ្សាយព័ត៌មានការងារ មុខរបរ និងជំនាញបច្ចេកទេស និងវិជ្ជាជីវៈ តាមរយៈគេហទំព័ររបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល និងតាមមធ្យោបាយផ្សព្វផ្សាយផ្សេងៗទៀត
- ធ្វើសហប្រតិបត្តិការ សម្របសម្រួលជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ដែលត្រូវការកំលាំងពលកម្ម និងតម្រូវការជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីលើកអនុសាសន៍ជូនគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- ផ្តល់ទិន្នន័យជាក់លាក់ស្តីពីព័ត៌មានការងារ ដើម្បីជាមូលដ្ឋានក្នុងការជួយសម្រួលដល់រាជរដ្ឋាភិបាលឱ្យមានលទ្ធភាពរៀបចំផែនការអភិវឌ្ឍន៍ធនធានមនុស្ស និងទីផ្សារការងារដ៏ត្រឹមត្រូវ ហើយឈានសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្រ សម្រាប់កាត់បន្ថយភាពក្រីក្រតាមរយៈការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការផ្តល់ឱកាសការងារដល់ប្រជាពលរដ្ឋ និង
- បំពេញភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល ។

**មាត្រា ៤.-**

សិទ្ធិ និងការទទួលខុសត្រូវរបស់ប្រធាន **ន.ជ.ម.ក.** ត្រូវកំណត់ឱ្យបានច្បាស់លាស់នៅក្នុងល័ក្ខខ័ណ្ឌបេសកកម្ម និងកិច្ចសន្យាគ្រប់គ្រង ។

ល័ក្ខខ័ណ្ឌបេសកកម្ម និងកិច្ចសន្យាគ្រប់គ្រងគំរូ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ៥.-**

**ន.ជ.ម.ក.** ត្រូវដឹកនាំ និងគ្រប់គ្រងដោយប្រធានមួយរូប ដែលមានឋានៈស្មើអគ្គនាយក និងអមដោយអនុប្រធានមួយចំនួន ដែលមានឋានៈស្មើអគ្គនាយករងតាមការចាំបាច់ ។

ប្រធាន **ន.ជ.ម.ក.** ត្រូវទទួលខុសត្រូវក្នុងការរៀបចំដំណើរការ និងការគ្រប់គ្រងទីភ្នាក់ងារប្រតិបត្តិការពិសេសរបស់ខ្លួន ចំពោះគណៈកម្មាធិការជាតិបណ្តុះបណ្តាល ។

ប្រធាន **ន.ជ.ម.ក.** ត្រូវធ្វើរបាយការណ៍លទ្ធផល និងដំណើរការការងារជូនគណៈកម្មាធិការជាតិបណ្តុះបណ្តាល និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

## ជំពូកទី ៣

## រចនាសម្ព័ន្ធ

**មាត្រា ៦.-**

**ន.ជ.ម.ក.** មានបួនផ្នែក តាមរចនាសម្ព័ន្ធដូចខាងក្រោម :

- ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ

- ផ្នែកផែនការ និងសហប្រតិបត្តិការ
- ផ្នែកគ្រប់គ្រងប្រព័ន្ធព័ត៌មាន និង
- ផ្នែកប្រមូល និងផ្សព្វផ្សាយព័ត៌មាន។

ផ្នែកនីមួយៗ ត្រូវដឹកនាំ និងគ្រប់គ្រងដោយប្រធានមួយរូប ដែលមានឋានៈស្មើប្រធាននាយកដ្ឋាន និងអមដោយអនុប្រធានមួយចំនួន ដែលមានឋានៈស្មើអនុប្រធាននាយកដ្ឋានតាមការចាំបាច់។

**មាត្រា ៧.-**

ផ្នែកនីមួយៗ ត្រូវបែងចែកជាក្រុមការងារ។ ការកំណត់តួនាទី ភារកិច្ច និងការទទួលខុសត្រូវ ព្រមទាំងការចាត់តាំងប្រធានក្រុម ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ប្រធាន **ឆ.ជ.ម.ក.**។

**មាត្រា ៨.-**

**ឆ.ជ.ម.ក.** អាចបង្កើតមជ្ឈមណ្ឌលការងារ ដែលសរសេរកាត់ជា "ម.ក." នៅតាមទីកន្លែងណាមួយសមស្របតាមលទ្ធភាពជាក់ស្តែង និងតាមការចាំបាច់។

ម.ក.ត្រូវដឹកនាំ និងគ្រប់គ្រងដោយប្រធានមួយរូប។ ការកំណត់តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ ម.ក. ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ប្រធាន **ឆ.ជ.ម.ក.**។

**មាត្រា ៩.-**

ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ មានភារកិច្ចចម្បងៗ ដូចតទៅ :

- ចាត់ចែងចរាចរ និងគ្រប់គ្រងឯកសាររដ្ឋបាល
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារ
- គ្រប់គ្រងចំណូល និងចំណាយ
- គ្រប់គ្រងបុគ្គលិកមន្ត្រីរាជការ រៀបចំការងារបៀវត្សពលកម្ម ប្រាក់កម្រៃ របបឧបត្ថម្ភគោលនយោបាយវាយតម្លៃដំឡើងឋានៈ ឬ លើកទឹកចិត្ត ។ល។
- រៀបចំ តាក់តែងលិខិតបទដ្ឋាន លិខិតរដ្ឋបាលនានា ធ្វើកំណត់ហេតុរាល់អង្គប្រជុំសាមញ្ញ និង វិសាមញ្ញរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ
- ធ្វើរបាយការណ៍ការងារ និងកំណត់ហេតុផ្សេងៗរបស់ថ្នាក់ដឹកនាំ
- រៀបចំ និងសរុបរបាយការណ៍លទ្ធផល និងសកម្មភាព របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារជាប្រចាំ និងបូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

- ប្រមូលផ្តុំតម្រូវការនានា លើកគម្រោងស្នើសុំថវិកាជាតិ និងដៃគូអភិវឌ្ឍន៍ និងតាមដានរំលឹកពីការប្រតិបត្តិតាមឆ្នាំនីមួយៗ
- ផ្គត់ផ្គង់ និងគ្រប់គ្រងមូលដ្ឋានសំភារៈបរិក្ខារទីភ្នាក់ងារជាតិមុខរបរ និងការងារ និងអង្គភាពស្ថិតក្រោមឱវាទ
- គ្រប់គ្រងអចលនទ្រព្យ ចលនទ្រព្យ សន្និធិ សំភារៈ និងបញ្ជីសារពើភណ្ឌ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារប្រគល់ជូន ។

**មាត្រា ១០.-**

ផ្នែកផែនការ និងសហប្រតិបត្តិការ មានភារកិច្ចចម្បងៗ ដូចតទៅ :

- ប្រមូល រៀបចំ គ្រប់គ្រង ពិនិត្យ និងវិភាគទិន្នន័យលទ្ធផលការងារទទួលបានពីគ្រប់អង្គភាពពាក់ព័ន្ធ ដើម្បីកំណត់កម្មវិធីសកម្មភាព និងធ្វើគម្រោងផែនការ
- ធ្វើផែនការសកម្មភាពការងារ និងគម្រោងថវិការយៈពេលខ្លី មធ្យម និងវែងរបស់ទីភ្នាក់ងារជាតិ មុខរបរ និងការងារ
- ធ្វើទំនាក់ទំនង សម្របសម្រួល និងសហប្រតិបត្តិការក្នុង និងក្រៅប្រទេស ដោយសហការជាមួយផ្នែកជំនាញ
- រៀបចំពិធីការ និងដំណើរការរាល់កិច្ចប្រជុំ និងជំនួបពិភាក្សាផ្សេងៗរបស់ថ្នាក់ដឹកនាំ
- រៀបចំអនុស្សរណៈ ឬកិច្ចព្រមព្រៀងរវាងទីភ្នាក់ងារជាតិមុខរបរ និងការងារជាមួយក្រសួង ស្ថាប័ន អង្គការ និងបណ្តាប្រទេសនានា
- រៀបចំគម្រោងសហប្រតិបត្តិការទ្វេភាគី និងពហុភាគីជាមួយអង្គការ ស្ថាប័នជាតិ អន្តរជាតិនានា
- ពិនិត្យ តាមដាន និងវាយតម្លៃទាំងបរិមាណ និងគុណភាពការងារតាមជំនាញនីមួយៗ ដែលសម្រេចបាន
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនទីភ្នាក់ងារជាតិមុខរបរ និងការងារ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារប្រគល់ជូន ។

**មាត្រា ១១.-**

ផ្នែកគ្រប់គ្រងប្រព័ន្ធព័ត៌មាន មានភារកិច្ចចម្បងៗ ដូចតទៅ :

- បង្កើត រចនា និងអភិវឌ្ឍគេហទំព័រ
- រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងបញ្ចូលទិន្នន័យ
- ធ្វើបច្ចុប្បន្នភាពព័ត៌មាននៅលើគេហទំព័រឱ្យបានទាន់ពេលវេលាជាប្រចាំ
- ជួសជុល និងថែទាំប្រព័ន្ធកុំព្យូទ័រ

- តាមដាន និងអភិវឌ្ឍប្រព័ន្ធផ្ទុកទិន្នន័យជាប្រចាំ
- ធ្វើទំនាក់ទំនងជាមួយផ្នែកជំនាញផ្សេងៗ ដែលពាក់ព័ន្ធ ដើម្បីប្រមូលទិន្នន័យ និងបញ្ចូលទិន្នន័យ
- គ្រប់គ្រងគេហទំព័រ ដកស្រង់ព័ត៌មានប្រចាំថ្ងៃ និងរាយការណ៍
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារប្រគល់ជូន ។

**មាត្រា ១២.-**

ផ្នែកប្រមូល និងផ្សព្វផ្សាយព័ត៌មាន មានភារកិច្ចចម្បងៗ ដូចតទៅ :

- ធ្វើការផ្សព្វផ្សាយ និងផ្តល់សេវាព័ត៌មានទីផ្សារការងារដល់សិស្ស និស្សិត កម្មករ និយោជិត និងសាធារណជន ពិសេសអ្នកកំពុងស្វែងរកការងារធ្វើ
- រៀបចំឱ្យមានស្ថិតិសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនតាមប្រភេទមុខរបរ ចំណាត់ថ្នាក់ក្រុមហ៊ុន និងចំណាត់ថ្នាក់មុខរបរ
- រៀបចំឱ្យមានកញ្ចប់ព័ត៌មានរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនីមួយៗ
- រៀបចំផែនការអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានទីផ្សារការងារ
- ធ្វើទំនាក់ទំនងគ្រប់ផ្នែក អង្គភាព ស្ថាប័ន ដែលពាក់ព័ន្ធ ដើម្បីក្តាប់ឱ្យបាននូវព័ត៌មានទីផ្សារការងារ
- និពន្ធ ផលិត និងចងក្រងឯកសារ ផ្សព្វផ្សាយព័ត៌មានដោយសហការជាមួយគ្រប់ប្រព័ន្ធផ្សព្វផ្សាយ
- រៀបចំ ផលិតសៀវភៅរូបភាព ផ្ទាំងរូប ខ្សែមសារស្កត ប័ណ្ណផ្ទត់ ដែលទាក់ទងនឹងសកម្មភាពការងាររបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារប្រគល់ជូន ។

**មាត្រា ១៣.-**

មន្ត្រី ដែលបម្រើការងារក្នុង **ទ.ជ.ម.ក.** ជាមន្ត្រីក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ឬ បុគ្គលិកជាប់កិច្ចសន្យា។

មន្ត្រីរាជការ និងបុគ្គលិកទាំងនេះ ត្រូវចុះកិច្ចសន្យាការងារជាមួយប្រធាន **ទ.ជ.ម.ក.** តាមរយៈអ្នកគ្រប់គ្រងមន្ត្រីផ្ទាល់ ។

**មាត្រា ១៤.-**

មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា ដែលបម្រើការងារនៅ **ទ.ជ.ម.ក.** ត្រូវទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ដែលបានមកពីការបែងចែកប្រាក់កម្រៃសេវា និងប្រាក់ឧបត្ថម្ភផ្សេងៗទៀត បន្ថែមលើប្រាក់បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ។

## ជំពូកទី ៤

## ប្រភពធនធានហិរញ្ញវត្ថុ

**មាត្រា ១៥.-**

ប្រភពធនធាន និងចំណូលថវិការបស់ **គ.ជ.ម.គ.** បានមកពី :

- ថវិកាជាតិ ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ប្រាក់ ដែលបានមកពីការបែងចែកកម្រៃសេវា
- ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ និង
- ប្រភពផ្សេងៗទៀត ។

**មាត្រា ១៦.-**

ការកំណត់ថ្លៃសេវា និងការបែងចែកកម្រៃសេវា ត្រូវធ្វើឡើងដោយប្រកាសរួមរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈកម្មាធិការជាតិបណ្តុះបណ្តាល។

**មាត្រា ១៧.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ត្រូវធានានូវថវិកា ដែលត្រូវផ្តល់ឱ្យទីភ្នាក់ងារប្រតិបត្តិការពិសេសទាន់ពេលវេលា ។

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដែលជាសេនាធិការឱ្យទីស្តីការគណៈរដ្ឋមន្ត្រី មានតួនាទីសម្របសម្រួល ជំរុញ និងតាមដានការអនុវត្តន៍របស់ទីភ្នាក់ងារនេះ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៨.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៩.~**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មាធិការជាតិបណ្តុះបណ្តាល រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

សូមមេត្តាចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៩
- រាជកិច្ច ✓
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៨/៣៤៦ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីគោលការណ៍រួមនៃការបង្កើត និងដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស
- បានឃើញអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៨ ស្តីពីការអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៩ ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាព

- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ស្ថិតនៅក្រោមការដឹកនាំ និងត្រួតពិនិត្យផ្ទាល់របស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដើម្បីដឹកនាំ គ្រប់គ្រង និងត្រួតពិនិត្យរាល់ការបង្កើត និងការដាក់ឱ្យដំណើរការកម្មវិធីកន្សោមអាទិភាព ការអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ទីភ្នាក់ងារប្រតិបត្តិការពិសេស និងប្រព័ន្ធគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពនៃការបំពេញការងារ និងគណនេយ្យភាពនៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ។

**មាត្រា ២.-**

គណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១- ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | ប្រធាន |
| ២- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- អគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | សមាជិកអចិន្ត្រៃយ៍ |
| ៤ - តំណាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ៥ - តំណាងក្រសួងសុខាភិបាល | សមាជិក |
| ៦ - តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | សមាជិក |
| ៧ - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨ - តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៩ - តំណាងក្រសួង ស្ថាប័ន សាមី | សមាជិក |

គណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ត្រូវធានាឱ្យមានការចូលរួមពេញលេញពីគ្រប់ក្រសួង ស្ថាប័ន។

ការតែងតាំងសមាសភាពគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាពត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

មាត្រា ៣.-

គណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព មានភារកិច្ចចម្បងៗ ដូចខាងក្រោម :

- ផ្តល់មតិយោបល់លើចំណុចយុទ្ធសាស្ត្រ និងលក្ខណវិនិច្ឆ័យសំរាប់ការរៀបចំ ការបង្កើត ការគ្រប់គ្រង និងការតាមដានត្រួតពិនិត្យលើវាល់ដំណើរការនៃការអនុវត្តន៍កម្មវិធីកន្សោមអាទិភាព ប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ទីភ្នាក់ងារប្រតិបត្តិការពិសេស និងប្រព័ន្ធគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព
- សម្របសម្រួលលើអភិក្រមនៃការអនុមតិយល់ព្រមលើសំណើរបស់ក្រសួង ស្ថាប័ន
- ត្រួតពិនិត្យលើលទ្ធផលនៃការជ្រើសរើសមន្ត្រីរាជការនៅតាមក្រសួង ស្ថាប័នដែលនឹងត្រូវតែងតាំងឱ្យបំពេញការងារនៅទីភ្នាក់ងារប្រតិបត្តិការពិសេស កម្មវិធីកន្សោមអាទិភាព ប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ
- តាមដានត្រួតពិនិត្យ និងវាយតម្លៃលើយន្តការ និងដំណើរការនៃការអនុវត្តន៍ទីភ្នាក់ងារប្រតិបត្តិការពិសេស កម្មវិធីកន្សោមអាទិភាព និងប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ
- ធ្វើរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃការអនុវត្តន៍ទីភ្នាក់ងារប្រតិបត្តិការពិសេស កម្មវិធីកន្សោមអាទិភាព និងប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ និងផ្សព្វផ្សាយរបាយការណ៍នេះប្រចាំឆ្នាំឱ្យបានទៀងទាត់
- តាមដានត្រួតពិនិត្យការអនុវត្តន៍សេចក្តីសម្រេចនានាពាក់ព័ន្ធទៅនឹងការដាក់ឱ្យដំណើរការយន្តការខាងលើដែលធ្វើឡើងដោយក្រសួង ស្ថាប័ន
- បំពេញភារកិច្ចផ្សេងៗទៀត ដែលក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលប្រគល់ឱ្យ ។

មាត្រា ៤.-

គណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ត្រូវធ្វើអធិការកិច្ចចំពោះក្រសួង ស្ថាប័នដែលបានសុំបង្កើត និងដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស ឬ ក៏អនុវត្តកម្មវិធីកន្សោមអាទិភាព ឬ អនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ។

គណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាពត្រូវមានក្រុមការងារអធិការកិច្ចសំរាប់ធ្វើអធិការកិច្ចលើដំណើរការជ្រើសរើសមន្ត្រីឱ្យបំពេញការងារនៅក្នុងទីភ្នាក់ងារប្រតិបត្តិការពិសេស កម្មវិធីកន្សោមអាទិភាព និងការអនុវត្តន៍ប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ។

ក្នុងករណីចាំបាច់ គណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាពអាចស្នើសុំអន្តរាគមន៍ពីអាជ្ញាធរជាតិសវនកម្មដើម្បីជួយក្នុងការធ្វើអធិការកិច្ចនេះ ។

មាត្រា ៥. -

ការបង្កើត និងការតែងតាំងសមាសភាពក្រុមការងារអធិការកិច្ច ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ។

មាត្រា ៦. -

អនុប្រធាន និងសមាជិកគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រធានគណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាពអាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងតំណាងដៃគូអភិវឌ្ឍន៍ឱ្យចូលរួមការប្រជុំតាមការចាំបាច់ ។

មាត្រា ៧. -

គណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ត្រូវអនុវត្តភារកិច្ចរបស់ខ្លួនឱ្យបានម៉ឺងម៉ាត់ និងមានស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីសម្រេចឱ្យបានជោគជ័យនូវទិសដៅរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ។

គ្រប់ក្រសួង ស្ថាប័ន ត្រូវសហការ និងជំរុញឱ្យមានប្រសិទ្ធភាពក្នុងការបង្កើត ការគ្រប់គ្រង និងការតាមដានត្រួតពិនិត្យលើការអនុវត្តន៏កម្មវិធីកន្សោមអាទិភាព ប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ទីភ្នាក់ងារប្រតិបត្តិការពិសេស និងប្រព័ន្ធគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ។

មាត្រា ៨. -

គណៈកម្មាធិការគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព មានអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ជាលេខាធិការដ្ឋានសំរាប់បំពេញការងារ ។

មាត្រា ៩. -

គ្រប់ក្រសួង ស្ថាប័ន ត្រូវបង្កើតក្រុមការងារគ្រប់គ្រងប្រសិទ្ធភាពការងារ និងគណនេយ្យភាព ដើម្បីសម្របសម្រួលការរៀបចំសំណើ ការបង្កើត ការដាក់ឱ្យដំណើរការ ការគ្រប់គ្រង និងតាមដានត្រួតពិនិត្យការអនុវត្តន៍ទីភ្នាក់ងារប្រតិបត្តិការពិសេស កម្មវិធីកន្សោមអាទិភាព និងប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ។

មាត្រា ១០. -

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

នៃព្រះរាជាណាចក្រកម្ពុជា សូមមេត្តាចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**សុខ អាន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- ដូចមាត្រា ១១
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៨៧ . អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន១១៣រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនទីស្តីការគណៈរដ្ឋមន្ត្រី កន្លងមក ដូចមានរាយនាមខាងក្រោម :-

**ក_មេដាយមាសការងារ :**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **គង់** | **ថៃ** | សមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ |
| ២-ឯកឧត្តម | **លឿង** | **ស៊ីម៉ូណា** | អគ្គលេខាធិការរង ក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ |
| ៣-ឯកឧត្តម | **រោង** | **ឈុង** | អគ្គលេខាធិការគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍ |
| ៤-ឯកឧត្តម | **ស៊ា** | **ម៉ៅ** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ |
| ៥-ឯកឧត្តម | **អ៊ុំ** | **ប៊ុម** | អគ្គលេខាធិការរងរាជបណ្ឌិតសភាកម្ពុជា |
| ៦-លោក | **ហ៊ុង** | **គីមហៀង** | ប្រធានផ្នែកនៃអគ្គលេខាធិការដ្ឋាន ក្រុមសង្កេតការណ៍ សេដ្ឋកិច្ច ស.កិច្ច និងវប្បធម៌ |
| ៧-លោក | **ប៊ិច** | **សុខា** | ប្រធានផ្នែកនៃអគ្គលេខាធិការដ្ឋាន ក្រុមសង្កេតការណ៍ សេដ្ឋកិច្ច ស.កិច្ច និងវប្បធម៌ |
| ៨-លោក | **កៅ** | **ធារ៉ូ** | អគ្គនាយករងនៃអាជ្ញាធរប្រេងកាតជាតិកម្ពុជា |
| ៩-លោក | **ញឹក** | **សុមេធ** | អនុប្រធានផ្នែក នៃអាជ្ញាធរប្រេងកាតជាតិកម្ពុជា |
| ១០-លោក | **អ៊ុង** | **ផានី** | ប្រធានផ្នែករដ្ឋបាល នៃអាជ្ញាធរប្រេងកាតជាតិកម្ពុជា |
| ១១-លោក | **គង់** | **ចន្ធី** | ប្រធានការិ.នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ |

១២-លោក **អ៊ុំ សុទ្ធី** ប្រធានផ្នែកនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់

១៣-លោកស្រី **នួន ប៊ុនធឿន** អនុប្រធានផ្នែកនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់

១៤-លោក **នូ រិទ្ធី** អនុប្រធាននាយកដ្ឋានសរុប

១៥-លោក **សារុន រ៉ាឌី** អនុប្រធាននាយកដ្ឋានអាស៊ាន

១៦-លោក **សេង ស៊ីន** អនុប្រធាននាយកដ្ឋាន ឧស្សាហកម្ម និងសំណង់

១៧-លោក **តាត់ ចាន់ថា** លេខាអចិន្ត្រៃយ៍ វិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា នៃរាជបណ្ឌិតសភាកម្ពុជា

១៨-លោក **សន ពៅ** លេខាអចិន្ត្រៃយ៍ វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិតសភាកម្ពុជា

១៩-លោក **សំ ប៊ុនណា** អនុប្រធាននាយកដ្ឋានបុគ្គលិក

**ខ-មេដាយប្រាក់ការងារ :**

១-លោកស្រី **ស សំណាង** ប្រធានការិយាល័យ នៃនាយកដ្ឋានគមនាគមន៍ និង ប្រៃសណីយ៍

២-លោកស្រី **អៀល សុផេត** ប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាល

៣-លោក **ភាំង ទ៉ាន់ថា** មន្ត្រី នាយកដ្ឋានឧស្សាហកម្ម និង សំណង់

៤-លោក **មួន ហ៊ុំងសុធីយ៉ា** អគ្គនាយករង រាជកិច្ច និងសេវាកុំព្យូទ័រ

៥-លោកស្រី **ពេជ្រ ចាន់ណាត្រី** ប្រធាននាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

៦-លោក **យឹម រុទ្សី** អនុប្រធាននាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

៧-លោក **ផាត់ លាលីន** អនុប្រធាននាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

៨-ឯកឧត្តម **ព្រហ្ម វិចិត្រអក្ខរា** សមាជិកបម្រុង ក្រុមប្រឹក្សាអ្នកច្បាប់

៩-លោក **លឹម ឆាយ** អនុប្រធានការិយាល័យទំនាក់ទំនងសាធារណៈ នៃ ន.ទំនាក់ទំនងអន្តរជាតិ

១០-លោក **បេង បឿន** មន្ត្រី នៃនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ

១១-លោក **សួស វិសុទ្ធ** ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ

១២-លោកស្រី **សូ សារិន** អនុប្រធានលេខាធិការដ្ឋាន នៃអគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ

១៣-លោក **ព្រាំ កុសល** អនុប្រធាននាយកដ្ឋានផែនការ និងសហប្រតិបត្តិការ

១៤-លោក **គីម សោវឌី** អនុប្រធាននាយកដ្ឋានសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល និង សិទ្ធិមនុស្ស

១៥-លោក **ជីង ផេងស្រួយ** ប្រធានក្រុមគម្រោង នៃ អង្គភាពគ្រប់គ្រងគម្រោង នៃ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

១៦-លោក **ជាវ បុត្រតារា** អនុប្រធានផ្នែកនៃលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

១៧-លោក **លី ជាវណា** អនុប្រធានផ្នែកនៃលេខាធិការដ្ឋានក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

១៨-លោក **លឹម វុត្ថា** អនុប្រធានផ្នែកនៃអាជ្ញាធរប្រេងកាតជាតិកម្ពុជា

១៩-លោក **ដួង សុធី** អនុប្រធានផ្នែក នៃអាជ្ញាធរប្រេងកាតជាតិកម្ពុជា

២០-លោក **ឃុន សូណា** មន្ត្រីរាជបណ្ឌិតសភា វិជ្ជាជីវៈ តុលាការ

២១-លោក **សុខ ឃន** អនុប្រធាននាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋានគុណភាពអប់រំ នៃកម្ពុជា

២២-លោកស្រី **ស្រី ម៉ាលីន** អនុប្រធាននាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋានគុណភាពអប់រំ នៃកម្ពុជា

២៣-លោក **ពៅ វណ្ណនី** អនុប្រធាននាយកដ្ឋាន នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំ នៃកម្ពុជា

| | | | |
|---|---|---|---|
| ២៤-លោកស្រី | អ៊ុក | ទូច | អនុប្រធានផ្នែក នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល |
| ២៥-លោកស្រី | ឆាយ | គីមសុទ្ធី | អនុប្រធានផ្នែក នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល |
| ២៦-លោក | សយ | រាស៊ី | អនុប្រធានផ្នែក នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល |
| ២៧-លោក | ឈុប | សុធារ៉ា | អនុប្រធានផ្នែក នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល |
| ២៨-លោកស្រី | ផ្លែក | វីណែត | អនុប្រធានផ្នែក នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល |
| ២៩-លោក | ជី | ឧត្តម | អនុប្រធានផ្នែក នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល |
| ៣០-លោក | ហាក់ | សីលា | ប្រធានការិយាល័យនៃនាយកដ្ឋានកសិកម្ម |
| ៣១-លោក | កោះ | កល្យាណ | ប្រធានការិយាល័យនៃនាយកដ្ឋានពាណិជ្ជកម្ម ហិរញ្ញវត្ថុនិងធនាគារ |
| ៣២-លោក | គាន | ឆន | មន្ត្រីនាយកដ្ឋានពាណិជ្ជកម្ម ហិរញ្ញវត្ថុ និងធនាគារ |
| ៣៣-លោក | ថោង | សុគន្ធ | ប្រធានការិយាល័យនៃនាយកដ្ឋានអប់រំ សង្គមកិច្ច និងវប្បធម៌ |
| ៣៤-លោកស្រី | ឆេព | សារ៉េម | មន្ត្រីនាយកដ្ឋានពិធីការ |
| ៣៥-លោកស្រី | ឌុច | ចន្ធី | មន្ត្រីនាយកដ្ឋានពិធីការ |
| ៣៦-លោក | សុខ | ថុល | សមាជិកអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់ |
| ៣៧-លោក | ទា | ចំន្ទីរ៉ា | ប្រធានផ្នែកនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រជាជននិងការអភិវឌ្ឍ |
| ៣៨-លោក | ហេង | សុជា | ប្រធានការិយាល័យនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| ៣៩-លោក | អ៊ឹម | សួរ | ប្រធាននាយកដ្ឋាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ៤០-លោក | កយ | ផាត | មន្ត្រីនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ៤១-លោក | ឈាង | ហុង | ប្រធានការិយាល័យនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា |
| ៤២-លោក | គីម | សីហា | ប្រធានការិយាល័យនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា |
| ៤៣-លោកស្រី | ព្រាំ | កល្យាណ | ប្រធានការិយាល័យនៃនាយកដ្ឋានអាស៊ាន |
| ៤៤-លោក | ស៊ិន | ពិសិដ្ឋ | មន្ត្រីរាជបណ្ឌិតសភាកម្ពុជា |
| ៤៥-លោក | លី | សុធីរត្ន | ប្រធានគណនេយ្យ នៃរាជបណ្ឌិតសភាកម្ពុជា |
| ៤៦-លោក | ឃិន | យ៉ង់ | មន្ត្រីរាជបណ្ឌិតសភាកម្ពុជា |
| ៤៧-លោក | នង | កាឌីណាល់ | មន្ត្រីរាជបណ្ឌិតសភាកម្ពុជា |
| ៤៨-លោក | ឆេង | ខណ្ណារិទ្ធិ | ប្រធានផ្នែក នៃរាជបណ្ឌិតសភាកម្ពុជា |
| ៤៩-លោក | ហាក់ | ធីរោ | ប្រធានផ្នែក នៃរាជបណ្ឌិតសភាកម្ពុជា |
| ៥០-លោក | ជួរ | គារី | ប្រធានផ្នែក នៃរាជបណ្ឌិតសភាកម្ពុជា |
| ៥១-លោក | លាង | សុភាព | អនុប្រធានផ្នែក នៃរាជបណ្ឌិតសភាកម្ពុជា |
| ៥២-លោក | នុត | សម្បត្តិ | ប្រធានផ្នែក នៃរាជបណ្ឌិតសភាកម្ពុជា |
| ៥៣-លោក | កង | ស្រួយ | អនុប្រធានការិយាល័យ នៃនាយកដ្ឋានបុគ្គលិក |

គ-មេដាយសេរីវឌ្ឍការងារ :

| | | | |
|---|---|---|---|
| ១-លោក | រាជ | ខ្សេន | អនុប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាល |
| ២-លោកស្រី | ឃុន | រ៉ូហ្សាលី | អនុប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាល |
| ៣-លោកស្រី | ខិន | សន្ធី | មន្ត្រី នាយកដ្ឋានរដ្ឋបាល |
| ៤-លោក | ឱម | ចន្ទតារា | មន្ត្រី នាយកដ្ឋានព័ត៌មាន និងសារគមនាគមន៍ |

៥-លោក ឌូ សឿន មន្ត្រី សាលាភូមិន្ទរដ្ឋបាល

៦-លោក អ៊ុំ ម៉ុន មន្ត្រី អគ្គនាយកដ្ឋានរាជកិច្ច សេវាកុំព្យូទ័រ

៧-លោក អ៊ុច សារិន មន្ត្រី អគ្គនាយកដ្ឋានរាជកិច្ច សេវាកុំព្យូទ័រ

៨-លោកស្រី ម៉ែន គុលម៉ាលី មន្ត្រី នាយកដ្ឋានសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល និងសិទ្ធិមនុស្ស

៩-លោក ស៊ុន សិរីទុច មន្ត្រី អង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

១០-លោក ហ៊ួត រ៉ា មន្ត្រី លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

១១-លោក ម៉ែន ចាន់នៅ មន្ត្រី លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

១២-លោក លាង ឆាលី អគ្គនាយករង នៃអាជ្ញាធរប្រេងកាតជាតិកម្ពុជា

១៣-លោក អ៊ុង រ៉ានី មន្ត្រី អាជ្ញាធរប្រេងកាតជាតិកម្ពុជា

១៤-លោក ស៊ុន គួន មន្ត្រី អាជ្ញាធរប្រេងកាតជាតិកម្ពុជា

១៥-លោក ចាប សំណាង មន្ត្រី អាជ្ញាធរប្រេងកាតជាតិកម្ពុជា

១៦-លោក ម៉ែន ពិសិដ្ឋ មន្ត្រី អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

១៧-លោក គង់ ធីរិទ្ធ មន្ត្រី នាយកដ្ឋានកសិកម្ម

១៨-លោក ចោត ចាន់ណារី មន្ត្រី នាយកដ្ឋានពាណិជ្ជកម្ម ហិរញ្ញវត្ថុ និងធនាគារ

១៩-លោក មាស សុផល មន្ត្រី នាយកដ្ឋានពិធីការ

២០-លោកស្រី សុទ្ធ ចាន់ធីន មន្ត្រី នាយកដ្ឋានពិធីការ

២១-លោក ជ័យ ណារ៉ុង មន្ត្រី នាយកដ្ឋានពិធីការ

២២-លោក នៅ សុតគ្រា អនុប្រធាននៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការប្រជាជននិងការអភិវឌ្ឍ

២៣-លោក ម៉ម ចាន់ អនុប្រធានការិយាល័យ នៃនាយកដ្ឋានតំកល់ឯកសារជាតិ

២៤-លោកស្រី ម៉ែត ចាក់ អនុប្រធានការិយាល័យ នៃនាយកដ្ឋានតំកល់ឯកសារជាតិ

២៥-លោក គង់ តារី មន្ត្រី នាយកដ្ឋានតំកល់ឯកសារជាតិ

២៦-លោកស្រី កែវ ពៅ មន្ត្រី នាយកដ្ឋានតំកល់ឯកសារជាតិ

២៧-លោក ឈុយ ចាន់ឈួន មន្ត្រី រាជបណ្ឌិតសភាកម្ពុជា

២៨-លោក យឹម អាយុទឡ្ហនះទិដ្ឋា មន្ត្រី រាជបណ្ឌិតសភាកម្ពុជា

២៩-លោក យិន ពោ មន្ត្រី រាជបណ្ឌិតសភាកម្ពុជា

៣០-លោក ផុន ភសិភា មន្ត្រី រាជបណ្ឌិតសភាកម្ពុជា

៣១-លោក ឈត ម៉ុនថង មន្ត្រី រាជបណ្ឌិតសភាកម្ពុជា

៣២-លោក សំ ពិសិដ្ឋ មន្ត្រី រាជបណ្ឌិតសភាកម្ពុជា

៣៣-លោក នូ ឌីឡា មន្ត្រី រាជបណ្ឌិតសភាកម្ពុជា

៣៤-លោក កៅ មុយសាន មន្ត្រី រាជបណ្ឌិតសភាកម្ពុជា

៣៥-លោកស្រី ខា ទណ្ណី មន្ត្រី រាជបណ្ឌិតសភាកម្ពុជា

៣៦-លោក លាវ ផារុន មន្ត្រី រាជបណ្ឌិតសភាកម្ពុជា

៣៧-លោក មាឃ បូរ៉ា មន្ត្រី រាជបណ្ឌិតសភាកម្ពុជា

៣៨-លោក សោម សុផារ៉ាត មន្ត្រី អគ្គនាយកដ្ឋានអាជ្ញាធរអប្សរា

៣៩-លោក អ៊ុក តុបបុត្រា មន្ត្រី អគ្គនាយកដ្ឋានអាជ្ញាធរអប្សរា

៤០-លោក **ម៉ែន ភិរុណ** មន្ត្រី អគ្គនាយកដ្ឋានអាជ្ញាធរអប្សរា

៤១-លោក **ឡៅ ចុងចុនា** អនុប្រធានការិយាល័យ នៃនាយកដ្ឋានបុគ្គលិក

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៨៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខតំណែងនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានតែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់ ចំនួន ០២ នាក់ ដូចខាងក្រោម :

១-លោកឧត្តមសេនីយ៍ត្រី **ម៉ែន ទិបុល** អត្តលេខ ០៣៧៦ ជាទីប្រឹក្សាឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ថែមលើមុខងារបច្ចុប្បន្ន ។

២-លោកឧត្តមសេនីយ៍ត្រី **ជុំ សុឃាត** អត្តលេខ ០៣១៩ ជាទីប្រឹក្សាក្រសួងមហាផ្ទៃ ទទួលបន្ទុកការងារស្រាវជ្រាវជីករុករកអដ្ឋិធាតុជនជាតិបរទេសបាត់ខ្លួននៅកម្ពុជា ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

__កន្លែងទទួល :__
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៨៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **ធិបឌិន្ទ** ជូនតំណាងក្រុមហ៊ុន និង មន្ត្រីរាជការ ចំនួន ០៥ រូប ដែលមានគុណបំណាច់ និងស្នាដៃល្អ ក្នុងការកសាង អភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធ វិស័យគមនាគមន៍ និង ដឹកជញ្ជូន នៅខេត្តស្ទឹងត្រែង ដូចមានរាយនាមខាងក្រោម :-

| | | | | |
|---|---|---|---|---|
| ១- | លោក | **វ៉ូ** | **មិញថាញ** | ប្រធានក្រុមហ៊ុន ឌីស្ទឹងត្រែង មីនើរ៉ល យ៉ាញ វ៉េនឈ័រ ខមភេនី |
| ២- | លោក | **ឡៅ** | **យូហៀង** | សមាជិកក្រុមហ៊ុន ឌីស្ទឹងត្រែង មីនើរ៉ល យ៉ាញ វ៉េនឈ័រ ខមភេនី |
| ៣- | លោក | **ឡេវៀង** | **មិញ** | តំណាងការិយាល័យ VINA COMIN នៅកម្ពុជា |
| ៤- | លោក | **វ៉ូវ** | **ថេង** | សមាជិកក្រុមហ៊ុន ឌីស្ទឹងត្រែង មីនើរ៉ល យ៉ាញ វ៉េនឈ័រ ខមភេនី |
| ៥- | លោក | **ជា** | **ថាវរិទ្ធ** | អភិបាលស្រុកថាឡាបរិវ៉ាត់ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងនាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ : ៥៨៩ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៩០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ំ រេ ច

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០៣ នាក់ ដូចមានរាយនាមខាងក្រោម :

១- លោកវរសេនីយ៍ទោ **ចែម សាធាន** អត្តលេខ ០១៨៤៩
២- លោកវរសេនីយ៍ទោ **សុខ ពិសិដ្ឋ** អត្តលេខ ០២៣៣៦
៣- លោកវរសេនីយ៍ទោ **អ៊ុន សេរីរត្ន** អត្តលេខ ០៥៩៣៥ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល :*
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៩០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខតំណែងនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៩ ស្តីពីការកែសម្រួលនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹត្យការនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ទោ **និត សារ៉ាត់** អត្តលេខ ០៨២២ ជាប្រធាននាយកដ្ឋានបណ្តុះបណ្តាល នៃបណ្ឌិត្យសភានគរបាលកម្ពុជា ក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល :*
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៧១ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពី
# ការអនុវត្តវិន័យនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានអនុវត្តវិន័យវរសេនីយ៍ឯក **រាជ សំណាង** អត្តលេខ ០៤០៦ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដោយរូបភាពដកហូតឋានន្តរសក្តិថ្នាក់វរសេនីយ៍ឯក ។

**មាត្រា ២ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ និងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៥៩៧ អនក្រ.បក**

# អនុក្រឹត្យ

## ស្ដីពី

## ការតែងតាំងសមាសភាពគណៈកម្មការសុរិយោដីថ្នាក់ជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# ស ម្រេ ច

**មាត្រា ១.-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **អ៊ឹម ឈុនលឹម** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២. ឯកឧត្តម | **ប្រាំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៣. ឯកឧត្តម | **ឆេង នន្ទរី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ*
- *ដូចមាត្រា ៣*
- *រាជកិច្ច* ✓
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ ៥៩៣ អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# ការផ្លាស់ប្តូរសមាជិកនៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៤ ស្តីពីការកែប្រែមាត្រា ៤ នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ស្តីពីការកែប្រែមាត្រា ៤ថ្មី នៃអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៤ ស្តីពីការកែប្រែមាត្រា ៤ នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ២៧៧ អនក្រ.តត ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ ស្តីពីការតែងតាំងសមាជិកនៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# ស ម្រេ ច

**មាត្រា ១.-**

ត្រូវបានតែងតាំងឯកឧត្តម **ឈូន ដារ៉ា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ជាសមាជិកនៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ជំនួសឯកឧត្តម **ខិត ម៉ុន**។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- ដូចមាត្រា ៣
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៧៤ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ឯកឧត្តម **សើ កុសល** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស

## ស ម្រេ ច

**មាត្រា ១:** ត្រូវបានតែងតាំងជំនួយការឯកឧត្តម **សើ កុសល** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ដូចមានរាយនាមខាងក្រោម :

១-លោក **ឃិន ច័ន្ទតុលា** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**

២-លោកស្រី **ឃិន សោភា** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ..៥៩៥.....អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែ វិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និង កែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៨.អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយដ្ឋានរតនាគារជាតិស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## <u>សម្រេច</u>

**មាត្រា១:** ត្រូវបានតែងតាំងលោក **គីម ផល្លា** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ជាប្រធាននាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ នៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៩

**<u>កន្លែងទទួល:</u>**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប "
- ដូចមាត្រា២
- ឯកសារ- កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៩៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន០៥រូប ដែលបានបរិច្ចាគធនធានជួយកសាងសាលាពុទ្ធិកបឋមសិក្សា និងសមិទ្ធផលផ្សេងៗទៀត នៅវត្តអង្គពន្លឺ ស្ថិតក្នុងឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

១-ព្រះតេជគុណ **នាក់ សំបូរ** អគ្គលេខាធិការធម្មទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំព្រះរាជាណាចក្រថៃ បច្ច័យ ចំនួន ១៦.៨៦២ ដុល្លារ

២-ឧបាសក **មាស សុភី** និង ឧបាសិកាធម្មិការ **លឹម ហួន** នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១៩.៧៥៦ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១-ឧបាសក **ឡូន សួន** សប្បុរសជននៅភ្នំពេញ ថវិកាចំនួន ៧.០៥១ ដុល្លារ

២-លោក **ពៅ ឈួន** និង ភរិយា នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៦.៥១៤ ដុល្លារ

៣-ឧបាសិកា **អ៊ួង យាំ** ព្រមទាំងបុត្រ នៅភ្នំពេញ ថវិកាចំនួន ៥.៥០៩ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួល បានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៥៩៧ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជន ចំនួន ០២ រូប ដែលមានគុណបំណាច់ និងស្នាដៃល្អ ក្នុងការចូលរួមជួយកសាង និងអភិវឌ្ឍន៍មូលដ្ឋាន នៅខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

១- ឯកឧត្តម **សេង ឈួន** ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី ហេង សំរិន

២- លោកជំទាវ **អ៊ុង មួយហួង សេង ឈួន** សប្បុរសជន

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៩៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជន ចំនួន ០៥ រូប ដែលមានគុណបំណាច់ និង ស្នាដៃល្អ ក្នុងការចូលរួមចំណែក ជួយកសាង និងអភិវឌ្ឍន៍មូលដ្ឋាន នៅខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **ស៊ឹម** | **ស៊ុនធីម** | ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី ហេង សំរិន |
| ២- | ឯកឧត្តម | **លី** | **អៀមឡាក់** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| ៣- | ឯកឧត្តម | **ស្វាយ** | **សុធី** | ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី ហេង សំរិន |
| ៤- | លោក | **សេខ** | **សាម៉ុឌី** | សប្បុរសជន |
| ៥- | វេជ្ជបណ្ឌិត | **កែវ** | **គៀតឆុហ្វ** | សប្បុរសជន |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៩៩. អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

**សម្រេច**

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រី ចំនួន ០២ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបម្រើជាតិ ដូចមានរាយនាមខាងក្រោម :-

១- ឯកឧត្តម **ចាន់ ជឿន** ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី ហេង សំរិន

២- ឯកឧត្តម **ណុប ប៊ុនធឿន** ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី ហេង សំរិន

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦០០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិរវជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ១២ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមកសាងសមិទ្ធផលផ្សេងៗ នៅខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :-

| | | | | |
|---|---|---|---|---|
| ១- | លោក | **កែ** | **សុខុម** | ថវិកា ២០.០០០ ដុល្លារអាមេរិក |
| ២- | លោក | **ណុប** | **ប៊ុនធឿន** | ថវិកា ១៨.៥០០ ដុល្លារអាមេរិក |
| ៣- | លោក | **លឹម** | **ចាន់សុភី** | ថវិកា ១៥.៥០០ ដុល្លារអាមេរិក |
| ៤- | លោក | **ឯម** | **ខ្មៅ** | ថវិកា ១៥.៥០០ ដុល្លារអាមេរិក |
| ៥- | លោក | **ជួន** | **សុខា** | ថវិកា ១៥.៥០០ ដុល្លារអាមេរិក |
| ៦- | លោក | **ផៃ** | **វិសាល** | ថវិកា ១២.៥០០ ដុល្លារអាមេរិក |
| ៧- | លោក | **លឹម** | **ឃុនម៉េង** | ថវិកា ១១.១០០ ដុល្លារអាមេរិក |
| ៨- | លោក | **លី** | **មករា** | ថវិកា ១១.០០០ ដុល្លារអាមេរិក |
| ៩- | លោក | **រិទ្ធ** | **សំអុល** | ថវិកា ១០.៨០០ ដុល្លារអាមេរិក |
| ១០- | លោក | **សុខ** | **សុវណ្ណរិទ្ធិ** | ថវិកា ១០.៨០០ ដុល្លារអាមេរិក |
| ១១- | លោក | **ឡុង** | **សម្បត្តិ** | ថវិកា ១០.៧០០ ដុល្លារអាមេរិក |

១២- ឯកឧត្តម **ជា ចុង** ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ថវិកា ១០.៥០០ ដុល្លារអាមេរិក

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦០១-អនក្រ-បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ចំនួន ១៦ រូប ដែលបានបរិច្ចាគធនធាន ចូលរួមជួយកសាងសមិទ្ធផលផ្សេងៗ នៅវត្តបាលីចាស់ វត្តជីរីយកទឹក និង វត្តក្តីទន្ទឹម ស្រុកសំរោង ខេត្តតាកែវ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **ឡុង នៅ** | ព្រះចៅអធិការវត្តក្តីទន្ទឹម | បច្ច័យចំនួន ១៨.០០០ ដុល្លារ |
| ២-ព្រះតេជគុណ | **គីម ភាដាលីម** | ព្រះចៅអធិការវត្តជីរីយកទឹក | បច្ច័យចំនួន ១០.០០០ ដុល្លារ |
| ៣-ឯកឧត្តម | **ស្រ៊ុន សារឿន** | មេបញ្ជាការកងពលតូចលេខ៣១ | ថវិកាចំនួន ២៥.៧០០ ដុល្លារ |
| ៤-លោក | **សុខ សយ** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ថវិកាចំនួន ២៤.៨០០ ដុល្លារ |
| ៥-លោក | **ភុយ សុខ** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ថវិកាចំនួន ២៤.៥០០ ដុល្លារ |
| ៦-លោក | **ជា សុខ** | ធនាគារអេស៊ីលីដា ភីអិលស៊ី | ថវិកាចំនួន ១៣.៥០០ ដុល្លារ |
| ៧-លោក | **ហែម សុវិញ្ញូ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១២.៤០០ ដុល្លារ |
| ៨-លោក | **ជា ពិសិដ្ឋ** | ប្រធានសាខាពន្ធដារខេត្តកំពត | ថវិកាចំនួន ១២.៤០០ ដុល្លារ |
| ៩-លោក | **ផេង លី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១១.៥០០ ដុល្លារ |
| ១០-លោក | **ណាប ហៀង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១១.០០០ ដុល្លារ |
| ១១-លោក | **ម៉ែន វ៉ូ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១១.០០០ ដុល្លារ |
| ១២-លោក | **យូ ហាំ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១១.០០០ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| -លោក | **កែវ សុវត្ថិ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៧.០០០ ដុល្លារ |

**គ-មេដាយសំរឹទ្ធស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោក | **ភា អាន** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ៣.៧០០ ដុល្លារ |
| ២-លោក | **ឈួន ចេង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៣.០០០ ដុល្លារ |
| ៣-លោក | **ខៀវ សំ** | សប្បុរសជននៅខេត្តតាកែវ | ថវិកាចំនួន ៣.០០០ ដុល្លារ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥០២ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ជូនលោក **នុត ខុន** ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តតាកែវ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ កន្លងមក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៧ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការសិក្សា វាយតម្លៃតំបន់អភិវឌ្ឍន៍អាងទឹកស្អាត និងរមណីយដ្ឋានក្បាលឆាយ ខេត្តព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់

## ស ម្រេ ច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការសិក្សា វាយតម្លៃតំបន់អភិវឌ្ឍន៍អាងទឹកស្អាត និងរមណីយដ្ឋានក្បាលឆាយ ខេត្តព្រះសីហនុ ដែលមានសមាសភាពដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **នេង សារឿន** | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ទទួលបន្ទុកជាអគ្គលេខាធិការ | ប្រធាន |
| ២- | ឯកឧត្តម **ម៉ុន ហ៊ាន** | រដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម | អនុប្រធាន |
| ៣- | ឯកឧត្តម **ហ៊ឹង ថុរ៉ាក់ស៊ី** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤- | ឯកឧត្តម **គោស៊ុំ សារឿត** | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ៥- | ឯកឧត្តម **សួន ចាន់ថន** | មេធាវីរាជរដ្ឋាភិបាល | សមាជិក |
| ៦- | ឯកឧត្តម **ឡុញ ហ៊ាល** | អគ្គនាយកបច្ចេកទេស នៃក្រសួងបរិស្ថាន | សមាជិក |
| ៧- | ឯកឧត្តម **ង៉ៃ ផាន** | អភិបាលរងខេត្តព្រះសីហនុ | សមាជិក |
| ៨- | លោក **ហង្ស ម៉ុណ្ណាក់** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៩- | លោក **ជា សំអាង** | អនុប្រធានរដ្ឋបាលព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |

| | | | | |
|---|---|---|---|---|
| ១០- | លោក | **យុន ហេង** | ប្រធាននាយកដ្ឋានវិភាគគំរោង និងការលើកទឹកចិត្ត<br>នៃគណៈកម្មាធិការវិនិយោគកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១១- | លោក | **តន់ សុខជា** | ប្រធាននាយកដ្ឋានទឹកស្អាត<br>ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១២- | លោក | **មុជ ឈុនហ៊ន** | ប្រធាននាយកដ្ឋានវារីអគ្គិសនី<br>ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១៣- | លោក | **សុទ្ធ ធី** | ប្រធាននាយកដ្ឋានបូកសរុបព័ត៌មានវិទ្យានិងទំនាក់ទំនងសាធារណៈ<br>នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | សមាជិក |
| ១៤- | លោក | **សុខ ផន** | នាយរងទី១ខុទ្ទកាល័យសាលាខេត្តព្រះសីហនុ | សមាជិក |

**ប្រការ ២ :** គណៈកម្មការសិក្សា វាយតម្លៃតំបន់អភិវឌ្ឍន៍អាងទឹកស្អាត និងរមណីយដ្ឋានក្បាលឆាយ ខេត្តព្រះសីហនុ មានភារកិច្ចដូចខាងក្រោម ÷

- ផ្តល់ការណែនាំជាទូទៅក្នុងការអនុវត្តគម្រោងថ្មី និងគម្រោងនានា ដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាល ក្នុងតំបន់ទីជម្រាលក្បាលឆាយខេត្តព្រះសីហនុ សំដៅគ្រប់គ្រងដោយនិរន្តរភាពនៃតំបន់ទីជម្រាលក្បាលឆាយ
- ធ្វើការសម្របសម្រួលជាមួយម្ចាស់គម្រោង និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីឱ្យការអនុវត្តគម្រោងនានាក្នុងតំបន់ទីជម្រាលក្បាលឆាយ ប្រព្រឹត្តទៅដោយរលូន គ្មានឧបសគ្គ និងសម្រេចបានជោគជ័យ
- សិក្សា វាយតម្លៃផលប៉ះពាល់ជាទូទៅចំពោះតំបន់ទីជម្រាលក្បាលឆាយទាំងមូល និងជំរុញការសហការរវាងអង្គភាព ស្ថាប័នពាក់ព័ន្ធនានា ដើម្បីធានាការគ្រប់គ្រងប្រកបដោយនិរន្តរភាព តំបន់ទីជម្រាលក្បាលឆាយ ។

**ប្រការ ៣ :** សេចក្តីសម្រេចលេខ ០៦ សសរ ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបង្កើតក្រុមការងារសិក្សា វាយតម្លៃតំបន់អភិវឌ្ឍន៍អាងទឹកស្អាត និងរមណីយដ្ឋានក្បាលឆាយ ក្រុងព្រះសីហនុ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អភិបាលខេត្តព្រះសីហនុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល :*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៤*
- *រាជកិច្ច* ✓
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣៤៥ សហវ-ប្រក

# ប្រកាស

## ស្តីពី

## ការអនុវត្តន៍កម្មវិធីលុបបំបាត់ពន្ធនាំចូល និង របាំងមិនមែនពន្ធលើពាណិជ្ជកម្មក្នុងអាស៊ាន សម្រាប់ចំណែកទី ២ នៃបញ្ជីផលិតផលបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ (ICT)

..................

## ឧបនាយករដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការចាត់តាំងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និង កែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញភាពចាំបាច់ក្នុងការបំពេញកាតព្វកិច្ចដែលមានចែងនៅក្នុងពិធីសារចូលរួមអនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌ អ៊ី-អាស៊ាន (e-ASEAN) ដែលបានចុះហត្ថលេខា នៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០០
- បានឃើញលិខិតលេខ ៤៦០៥ សហវ ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០២ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការសុំសេចក្តីសម្រេចលើបញ្ជីផលិតផលបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ (ICT) និង កម្មវិធីលុបបំបាត់ពន្ធនាំចូល និងរបាំងមិនមែនពន្ធលើពាណិជ្ជកម្មក្នុងអាស៊ានសម្រាប់ចំណែកទី ២ នៃបញ្ជី ICT និងការសម្រេចរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## សម្រេច

**ប្រការ ១ :** ប្រកាសឱ្យអនុវត្តកម្មវិធីលុបបំបាត់ពន្ធនាំចូល និង របាំងមិនមែនពន្ធលើពាណិជ្ជកម្មក្នុងអាស៊ានសម្រាប់ចំណែកទី ២ នៃបញ្ជីផលិតផលបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ (ICT)។

**ប្រការ ២ :** ប្រកាសនេះ ចាប់មានប្រសិទ្ធិភាពអនុវត្ត ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៩ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៩

**គាត ឈន់**

ចម្លងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន ខេត្ត ក្រុង

  " ដើម្បីជូនជ្រាប "
- អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារ
- នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ាន

  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**Kingdom of Cambodia**

Nation Religion King

**ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

**Ministry of Industry, Mines and Energy**

លេខ : [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៤៩៥/០៩ គ.វ.ក ចុះថ្ងៃទី១៧.០៣.២០០៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ជី ហ្វៀរ មេឌូហ្វេកឈ័រីង ខមភេនី ចុះថ្ងៃទី០៦.០៣.២០០៩

## សំរេច

**ប្រការ១ :**

- អនុញ្ញាតឱ្យក្រុមហ៊ុន ជី ហ្វៀរ មេនូហ្វេកឈ័រីង ខមភេនី តំណាងដោយ លោក PULLEN RICHARD NEIL សញ្ជាតិអង់គ្លេស អាយុ៣៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 761112401 ចុះថ្ងៃទី០៨.០៨.២០០៥ មានអាសយដ្ឋានបច្ចុប្បន្ន : Offshore Chambers, Po Box217 Apia, Samoa ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម :

ល.រ ឈ្មោះផលិតផល លេខចុះបញ្ជីផលិតផល ISIC Code

**១-ចំណីសត្វ(សត្វខ្លែ) និងផលិតផលផ្សេងៗទៀត ៣១២២**

**សម្រាប់សត្វចិញ្ចឹម**

-ផ្លាកឈ្មោះ រោងចក្រ : **" ឌី ហ្វែរ មេនូហ្វេកឈ័ររីង (THE FAIR MANUFACTURING LTD.)**

-ទីតាំងរោងចក្រ : ***" ផ្លូវលេខ៩៩៨ ភូមិ៤ សង្កាត់ច្បារអំពៅទី១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ***

**ប្រការ២ :**

-ម្ចាស់រោងចក្រត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឱ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណាផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណី ដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣ :**

-ម្ចាស់រោងចក្រ ត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យ ដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសំរេចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម លេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានាស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤ :**

ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬប្រគល់សិទ្ធិឱ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប៉ុន្តែក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និង គុណភាពផលិតផល របស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥ :**

ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាស ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬ ចាត់ឱ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦ :**

ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីខាងមុខរោងចក្រ ។

**ប្រការ៧:**

-មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹង និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឱ្យម្ចាស់រោងចក្រ មានសុពលភាព ០៣ឆ្នាំ តាមលក្ខខណ្ឌដូចខាងក្រោម :

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និង ផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូ ដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ជិកម្មរោងចក្រប្រចាំ ០៣ឆ្នាំ ។

**ប្រការ៨ :**

-ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាពនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩ :**

-ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឱ្យអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយនៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅក្នុងអំឡុងពេលសប្តាហ៍ទីមួយនៃខែមករានៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រនឹងត្រូវទទួលទោសប្បញ្ញត្តិតាមមាត្រា ៤៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:**

រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និង ការចុះបញ្ជីផលិតផល ។

**ប្រការ១១:**

លក្ខខណ្ឌនានា របស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ ។

**ប្រការ១២:**

ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល ១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:**

-ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចស្របតាមមាត្រា ៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹងមកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

-ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល រយៈពេល១ខែ យ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រ ជាស្ថាពរ ។

**ប្រការ១៤:**

អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀង១ខ្លួន ។

**ប្រការ១៥:**

ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ-សែម

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលារាជធានីភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ១៤" ដើម្បីអនុវត្ត "
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ: ......................................

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញលិខិតលេខ ៦៣៤/០៩ គ.វ.ក ចុះថ្ងៃទី២៦.០៣.២០០៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ហ្គោលដេន ហ្គេន ស៊ូ ខមភេនី អិល ធី ឌី ចុះថ្ងៃទី១៩.០៣.២០០៩

## សំរេច

**ប្រការ១** :

-អនុញ្ញាតឱ្យក្រុមហ៊ុន ហ្គោលដេន ហ្គេន ស៊ូ ខមភេនី អិល ធី ឌី តំណាងដោយ លោកស្រី HUNG,WAN-YA សញ្ជាតិចិន (តៃវ៉ាន់) អាយុ៤៣ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 133038698 ចុះថ្ងៃទី១១.០៣.២០០២ មានអាសយដ្ឋានបច្ចុប្បន្ន : No 92, futian 1st St., South istrict Taichung City, Taiwan (R.O.C) ជាម្ចាស់

រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម :

| ល.រ ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Code |
|---|---|
| **១- ស្បែកជើង** | **៣២៤០** |

-ផ្លាកឈ្មោះ រោងចក្រ : " **ហ្គោលដេន ហ្គេន ស៊ូ ខមភេនី អិល ធី ឌី** **(GOLDEN GAIN SHOE COMPANY., LTD.)**"

-ទីតាំងរោងចក្រ : " ***ភូមិព្រៃទា សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ***"

**ប្រការ២ :**

-ម្ចាស់រោងចក្រត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឱ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណាផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណី ដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣ :**

-ម្ចាស់រោងចក្រ ត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យ ដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសំរេចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឱ្យប្រើ ដោយព្រះរាជក្រម លេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានាស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤ :**

ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬប្រគល់សិទ្ធិឱ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប៉ុន្តែក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និង គុណភាពផលិតផល របស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។/.

**ប្រការ៥ :**

ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាស ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬ ចាត់ឱ្យមករៀបចំរោងចក្របានឡើយ ។

**ប្រការ៦ :**

ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីខាងមុខរោងចក្រ ។

**ប្រការ៧:**

-មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹង និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឱ្យម្ចាស់រោងចក្រ មានសុពលភាព ០៣ឆ្នាំ តាមលក្ខខណ្ឌដូចខាងក្រោម :

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និង ផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូ ដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ឆ្នាំ ។

**ប្រការ៨ :**

-ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាពនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩ :**

-ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំជាបន្តបន្ទាប់ និងទៀងទាត់តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឱ្យអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយនៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកឱ្យអគ្គនាយកដ្ឋានឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល នៅក្នុងអំឡុងពេលសប្តាហ៍ទីមួយនៃខែមករានៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រនឹងត្រូវទទួលទោសប្បញ្ញត្តិតាមមាត្រា ៤៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:**

រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និង ការចុះបញ្ជីផលិតផល ។

**ប្រការ១១:**

លក្ខខណ្ឌនានា របស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ ។

**ប្រការ១២:**

ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល ១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:**

-ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចស្របតាមមាត្រា ៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្មឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹងមកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

-ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល រយៈពេល១ខែ យ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រ ជាស្ថាពរ ។

**ប្រការ១៤:**

ប្រកាសលេខ ៦៤១ ឧរថ.កឧ.ប្រក ចុះថ្ងៃទី១៤.០៦.២០០៦ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន រ៉នចិច អ៊ីភែរីល (ខេមបូឌា) ដែលមានទីតាំងស្ថិតនៅភូមិព្រៃទា សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១៥:**

អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀងៗខ្លួន ។

**ប្រការ១៦:**

ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ សែម

**ចម្លងជូន:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលារាជធានីភ្នំពេញ

  " ដើម្បីជូនជ្រាប "
- ដូចប្រការ១៥ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥០៥៤ ពណ.ចបព

ភ្នំពេញថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ២០០៨

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ដាយណែមិក អ៊ី - គ្រុប**
**DYNAMIC E - GROUP Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 12633/08P ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៨
មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **រ៉េត ចន្ថា**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៥៤៤ Eo វិថីកម្ពុជាក្រោម សង្កាត់ផ្សារដេប៉ូទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់-សិក្សាគំរោងប្លង់
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថសំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្តវីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ
-សេវាយកត់វេរជើងសារលើការដឹកជញ្ជូន
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ច មកតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចាំប៊ិក...

គឹម ស៊ីថន

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ -កាលប្បវត្តិ

ស.ជ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥០៥៥ ពណ.ចបព

ភ្នំពេញថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ ២០០៨

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

